# នីតិវិធីសម្រាប់ការបញ្ជាក់អំពីសិទ្ធិផ្ដាច់មុខលើម៉ាក ការកត់ត្រា និងការតម្កល់លិខិតប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក

# មាតិកា

១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ
២. និយមន័យ
៣. លក្ខខណ្ឌតម្រូវទាក់ទងការដាក់ពាក្យស្នើសុំ
៤. ឯកសារតម្រូវដាក់ពាក្យស្នើសុំកត់ត្រា
៥. លក្ខខណ្ឌតម្រូវទាក់ទងនឹងលិខិតប្រគល់សិទ្ធិផ្តាច់មុខ
៦. សិទ្ធិទទួលបានពីការកត់ត្រា
៧. សុពលភាពនៃការកត់ត្រា
៨. ការកម្រិតសិទ្ធិ
៩. រយៈពេលនៃបណ្តឹងតវ៉ា
១០. ការរំលោភបំពានសិទ្ធិ និងនីតិវិធីដោះស្រាយវិវាទ
១១.គំរូលិខិតប្រគល់សិទ្ធិផ្តាច់មុខ

# ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ

ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

- មាត្រា (៣)៖ សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវបានទទួលស្គាល់តាមរយៈការចុះបញ្ជី។
- មាត្រា១១ (គ)៖ សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាកនឹងមិនរាប់បញ្ចូលនូវការដាក់លក់ទំនិញនៅលើទីផ្សារ ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់ដែលបានចុះបញ្ជី ឬដោយមានការយល់ព្រមពីម្ចាស់ម៉ាកនោះទេ។

  - គោលការណ៍ផុតរលត់សិទ្ធិកម្រិតជាតិ (National Exhaustion of Rights)៖ សិទ្ធិផ្តាច់មុខរហូតដល់រាល់ទំនិញត្រូវបានលក់ និងទូទាត់រួចរាល់ក្នុងទីផ្សារក្នុងស្រុក

សារាចរណែនាំលេខ ០៧ សរណន របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ ស្តីពីការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក

ប្រកាសលេខ ០១១៧ ព.ណ កសប.ប្រក របស់ក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ ស្តីពី នីតិវិធីបញ្ជាក់ និងការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក

# និយមន័យ

- **"ការប្រគល់សិទ្ធិផ្តាច់មុខ"** ៖ ម្ចាស់ម៉ាកបរទេសជាអ្នកប្រគល់សិទ្ធិ គឺជាការព្រមព្រៀងដោយស្ម័គ្រចិត្ត រវាងអ្នកប្រគល់ និងអ្នកទទួលសិទ្ធិក្នុងការអនុញ្ញាតឱ្យអ្នកទទួលសិទ្ធិនៅកម្ពុជា នាំចូល និងចែកចាយទំនិញក្នុងទីផ្សារកម្ពុជា។
- **"លិខិតប្រគល់សិទ្ធិផ្តាច់មុខ"** ៖ លិខិតជាលាយលក្ខណ៍អក្សរ ធ្វើឡើងដោយអ្នកប្រគល់សិទ្ធិជូនទៅអ្នកទទួលសិទ្ធិនៅក្នុងប្រទេសកម្ពុជា អនុញ្ញាតឱ្យអ្នកទទួលសិទ្ធិនៅកម្ពុជា នាំចូល និងចែកចាយទំនិញក្នុងទីផ្សារកម្ពុជា ដោយមានការបញ្ជាក់អំពីម៉ាក ជំពូក យថាប្រភេទ និង/ឬ ម៉ូឌែលនៃទំនិញ។
- **"លិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក"** ៖ លិខិតរបស់ក្រសួងពាណិជ្ជកម្ម ដែលបានកត់ត្រាការប្រគល់សិទ្ធិផ្តាច់មុខ។
- **"លិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក"** ៖ លិខិតរបស់ក្រសួងពាណិជ្ជកម្ម ដែលបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក សម្រាប់ការនាំចូល និងចែកចាយទំនិញក្នុងទីផ្សារកម្ពុជា តាមការស្នើសុំរបស់ ម្ចាស់ម៉ាកជនជាតិខ្មែរ។

# លក្ខខណ្ឌតម្រូវទាក់ទងការដាក់ពាក្យស្នើសុំ

- អ្នកទទួលសិទ្ធិជានីតិបុគ្គល បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម
- ស្នើសុំកត់ត្រាក្នុងកំឡុងពេល ៦ ខែ នៃកាលបរិច្ឆេទកិច្ចសន្យាចូលជាធរមាននៃលិខិតប្រគល់សិទ្ធិ ឬបើមិនបានកំណត់ គិតចាប់ពីកាលបរិច្ឆេទចុះហត្ថលេខា
- អាចធ្វើការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខប្រើប្រាស់ម៉ាកលើទំនិញក្នុងជំពូកតែមួយ ដែលមានម៉ាកដូចគ្នា ប៉ុន្តែមានយថាប្រភេទ និងម៉ូឌែលខុសគ្នា ប្រសិនបើមានលិខិតប្រគល់សិទ្ធិផ្តាច់មុខពីម្ចាស់ដើម

# ឯកសារតម្រូវដាក់ពាក្យស្នើសុំកត់ត្រា

- ច្បាប់ដើមនៃលិខិតប្រគល់សិទ្ធិផ្តាច់មុខ (និង/ឬ លិខិតប្រគល់សិទ្ធិផ្តាច់មុខបន្ត) ក្នុងករណីប្រគល់សិទ្ធិបន្ត លិខិតប្រគល់សិទ្ធិផ្តាច់មុខពីម្ចាស់ដើមត្រូវមានចែងពីសិទ្ធិប្រគល់សិទ្ធិបន្ត
- លិខិតអនុញ្ញាតឱ្យនាំចូលចំពោះមុខទំនិញជាប់កម្រិតកំណត់
    - អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- ច្បាប់ចម្លងនៃវិញ្ញាបនបត្រចុះបញ្ជីម៉ាក ឬចុះបញ្ជីម៉ាកសាជាថ្មី
- ច្បាប់ចម្លងនៃលក្ខន្តិកៈក្រុមហ៊ុន សម្រង់ព័ត៌មាន និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- ច្បាប់ចម្លងនៃប័ណ្ណប៉ាតង់ និងវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមរបស់នីតិបុគ្គល
- វិក្កយបត្របង់ប្រាក់កម្រៃសេវាសាធារណៈ

# លក្ខខណ្ឌតម្រូវទាក់ទងនឹងលិខិតប្រគល់សិទ្ធិផ្តាច់មុខ

1. លិខិតប្រគល់សិទ្ធិត្រូវមានឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្រគល់សិទ្ធិ និង/ឬ អ្នកប្រគល់សិទ្ធិបន្ត
2. ឈ្មោះ និងអាសយដ្ឋានរបស់អ្នកទទួលសិទ្ធិ ជានីតិបុគ្គលចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម
3. ម៉ាក លេខចុះបញ្ជី ជំពូក និងយថាប្រភេទទំនិញ ឬម៉ូឌែលនៃទំនិញ

    *ចំពោះយានយន្ត ទោចក្រយាន ត្រីចក្រយានយន្ត ត្រូវមានបញ្ជាក់ពីម៉ាកនៃម៉ូឌែលនីមួយៗ យថាប្រភេទ ឬទំហំស៊ីឡាំងម៉ាស៊ីន និងប្រទេសផលិត*

4. ត្រូវតែបញ្ជាក់ថាអ្នកទទួលសិទ្ធិ មានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកក្នុងការនាំចូល ចែកចាយទំនិញ ក្នុងព្រះរាជាណាចក្រកម្ពុជា ( *Authorized Exclusive Distributor*)

# លក្ខខណ្ឌតម្រូវទាក់ទងនឹងលិខិតប្រគល់សិទ្ធិផ្តាច់មុខ

5. កាលបរិច្ឆេទសុពលភាព មានប្រសិទ្ធិភាពអនុវត្តនៃលិខិតប្រគល់សិទ្ធិ
6. សុពលភាពនៃលិខិត ដោយមិនឱ្យលើសពីរយៈពេល ១០ ឆ្នាំ
7. ឈ្មោះ និងហត្ថលេខារបស់អ្នកប្រគល់សិទ្ធិ និងកាលបរិច្ឆេទនៃការចុះហត្ថលេខា (ត្រូវបញ្ជាក់សាការីប្រទេសម្ចាស់ម៉ាក)

# សិទ្ធិទទួលបានពីការកត់ត្រា

- ម្ចាស់ម៉ាក ឬ អ្នកទទួលសិទ្ធិ ត្រូវផ្សព្វផ្សាយ លិខិតផ្តាច់មុខជាបន្ទាន់ ក្នុងទំព័រខាងមុខរបស់សារពត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្តាញសង្គមនានាឱ្យបានទូលំទូលាយ
- ចាប់ពីក្រោយរយៈពេល ៩០ ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រាឬបញ្ជាក់ពីសិទ្ធិផ្តាច់មុខ អ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។
- មានសិទ្ធិអនុវត្តទៅលើការនាំចូលស្របគ្នានូវទំនិញពាក់ម៉ាកដូចគ្នា ដោយភាគីទីបី ( PARALLEL IMPORTATION )

# សុពលភាពនៃការកត់ត្រា

- សុពលភាព ២ ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទកំណត់ក្នុងលិខិតរបស់ក្រសួងពាណិជ្ជកម្ម ឬអាចតិចជាងនេះយោងតាមសុពលភាពនៃ៖
  - លិខិតប្រគល់សិទ្ធិផ្តាច់មុខ
  - វិញ្ញាបនបត្រចុះបញ្ជីម៉ាក
  - លិខិតអនុញ្ញាតឱ្យនាំចូលផលិតផល

ការបន្តសុពលភាពនៃការកត់ត្រា

- ត្រូវស្នើសុំបន្តសុពលភាពការកត់ត្រា ៣០ ថ្ងៃ មុនកាលបរិច្ឆេទផុតសុពលភាពនៃលិខិតកត់ត្រា
- បើការស្នើសុំបន្តសុពលភាពក្រោយ ៣០ ថ្ងៃ នឹងចាត់ទុកការផ្តល់សុពលភាពកត់ត្រាថ្មី និងត្រូវអនុវត្តសិទ្ធិក្រោយរយៈពេល៩០ថ្ងៃ។

# ការបាត់បង់សុពលភាពនៃការកត់ត្រា

## ការបាត់បង់សុពលភាពដោយស្វ័យប្រវត្តិ

- ការប្រគល់សិទ្ធិផ្តាច់មុខត្រូវបានដកហូតវិញ ឬ
- សុពលភាពនៃការចុះបញ្ជីម៉ាកត្រូវបានបាត់បង់ដោយប្រការណាមួយ ឬ
- ម៉ាកត្រូវបានផ្ទេរកម្មសិទ្ធិ ឬ
- ការអនុញ្ញាតឱ្យនាំចូលទំនិញជាប់កម្រិតកំណត់ ត្រូវបានដកហូតវិញ

# ការកម្រិតសិទ្ធិ

មិនអាចកត់ត្រាសិទ្ធិនាំចូលផ្តាច់មុខ

- ទំនិញដែលបានប្រើរួចគ្រប់ប្រភេទ
- ផលិតផលឱសថ
- ជី និងថ្នាំកសិកម្ម
- មុខទំនិញហាមឃាត់ដូចមានចែងក្នុងបទប្បញ្ញត្តិជាធរមាន

ការកម្រិតសិទ្ធិ

- គោលការណ៍ផុតរលត់សិទ្ធិកម្រិតជាតិ (National Exhaustion of Rights)
- មិនអាចហាមឃាត់ការនាំចូលដោយស្ថាប័នរាជរដ្ឋាភិបាល ស្ថាប័ន និងអង្គការដែលមានកំណត់

# រយៈពេលនៃបណ្ដឹងតវ៉ា

- បុគ្គលពាក់ព័ន្ធមានសិទ្ធិប្ដឹងតវ៉ាទៅក្រុមប្រឹក្សាដោះស្រាយបណ្ដឹងតវ៉ានៃក្រសួងពាណិជ្ជកម្ម ឬតុលាការក្នុងរយៈពេល ៩០ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្ដីសម្រេចចេញលិខិតបញ្ជាក់សិទ្ធិផ្ដាច់មុខ ឬលិខិតកត់ត្រាសិទ្ធិផ្ដាច់មុខ។

- សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយនៃបណ្ដឹងតវ៉ានៃក្រសួងពាណិជ្ជកម្ម ជាកម្មវត្ថុនៃបណ្ដឹងតវ៉ាទៅតុលាការក្នុងរយៈពេល ៩០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយនៃបណ្ដឹងតវ៉ានៃក្រសួងពាណិជ្ជកម្ម ។

# ការរំលោភបំពានសិទ្ធិ និងនីតិវិធីដោះស្រាយវិវាទ

- ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ អាចចេញលិខិតព្រមានដល់អ្នកនាំចូលស្របគ្នាដទៃទៀត ដែលនាំចូលទំនិញក្រោមសិទ្ធិផ្តាច់មុខឲ្យបញ្ឈប់ការនាំចូលបំពានសិទ្ធិផ្តាច់មុខរបស់ខ្លួន។
- ក្រសួងពាណិជ្ជកម្មចេញលិខិតព្រមានដល់អ្នកនាំចូលស្របគ្នាដទៃទៀតដែលនាំចូលទំនិញក្រោមសិទ្ធិផ្តាច់មុខ តាមការស្នើសុំរបស់ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ។
- ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិនិងអ្នកនាំចូលស្របគ្នាដទៃទៀតអាចធ្វើការសម្របសម្រួលគ្នាបាន។

**Letter head**

**Ministry of Commerce**
Lot 19-61, MOC Road, (113B Road),
Teouk Thla Village, Sangkat Toeuk
Thla, Khan Sen Sok, Phnom Penh,
Cambodia

Re: **Authorized exclusive distributor *of the products bearing the marks* " ………………" which Registration Number………………. in Cambodia.**

**Dear Sir/Madam,**

We, the undersigned, ( ….Owner…….) having its registered office at……………………………….. hereby appoints (……Domestic Company….) having its registered at ……………………………Phnom Penh, Cambodia as our **exclusive distributor for all importing and distributing** the products bearing the above marks in Cambodia.

Besides them, no other company has the rights to import and distribute the said product bearing the above marks in Cambodia. The (….Owner…….) will not guarantee the quality of the products besides those imported and distributed by the appointed exclusive distributor.

This Exclusive letter is valid from …………… ……(day)……(month)……Year 20……..

Dated……(month)……Year 20__

Signed: ________________

Name: ________________

Position: ________________

I hereby certify that the above firm is a juristic person duly organized under the laws of ______________, and that the signature above is that of Mr/Mrs__________________ , (Position)________________, who is duly authorized to sign on behalf of the above-mentioned firm.

(Seal)

_________________________
Notary Public

# សូមអរគុណ!!!